ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តសៀមរាប

សាលាក្រុងសៀមរាប

សាលាសង្កាត់គោកចក

# សេចក្តីជូនដំណឹង ស្តីអំពី វិធីបង្ការ និងទប់ស្កាត់ នៃការប្រើប្រាស់គ្រឿងស្រវឹង

សាលាសង្កាត់គោកចក បានឃើញរបាយការណ៍ ស្តីអំពីផលប៉ះពាល់គ្រឿងស្រវឹងមកលើសុខភាព និងអំពើហឹង្សាក្នុងគ្រួសាររបស់ប្រជាពលរដ្ឋ នៅតាមមូលដ្ឋាន អង្គការ ភីឌីភី សឹងតែគ្រប់ករណី ។ ដោយមូលហេតុនេះ ក្រុមប្រឹក្សាសង្កាត់ទាំងអស់បានចូលរួមអនុម័ត ទៅលើសេចក្តីជូនដំណឹងអំពីៈ

**វិធីបង្ការ និងទប់ ស្កាត់នៃការ ប្រើប្រាស់ គ្រឿងស្រវឹង** នៅថ្ងៃទី **២៨** ខែ **វិច្ឆិកា** ឆ្នាំ **២០០៩** ។

**នៅក្នុងសេចក្តីជូនដំណឹងនេះមាន ៨ ចំណុចដែលមានខ្លឹមសារដូចខាងក្រោមៈ**

**១-** ក្មេងៗក្រោមអាយុ ១៨ ឆ្នាំ មិនត្រូវប្រើអោយទិញ ឬផឹកគ្រឿងស្រវឹងឡើយ ។

**២-** ហាមលក់គ្រឿងស្រវឹងគ្រប់ប្រភេទ នៅក្នុងវត្តអារាម សាលារៀន មណ្ឌលសុខភាព ។

**៣-** ហាមលើកប៉ាណូ ផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង គ្រប់ប្រភេទក្នុងទីតាំងឬក្រៅបរិវេណវត្តអារាម សាលារៀន មណ្ឌលសុខភាព ចន្លោះពី ២០ម ទៅ ៣០ម ។

**៤-** អ្នកផឹកទាំងឡាយហាមដើរបង្ខំគេអោយផឹកហួសម៉ោង ១០យប់ ។

**៥-** ចំពោះអ្នកផឹកទាំងឡាយ បើផឹកត្រូវមានករិតតាមច្បាប់ចរាចរណ៍ជើងគោក ។

**៦-** រៀងរាល់ពិធីបុណ្យផ្សេងៗហាមផឹកស្រាក្នុងរោងបុណ្យ ។

**៧-** ហាមផ្សព្វផ្សាយផ្ទាំងរូបភាព គ្រប់ប្រភេទពីគ្រឿងស្រវឹងនៅជុំវិញតូបលក់ដូរ ។

**៨-** ហាមយកសំបកកំប៉ុងស្រាបៀរដាក់ជើងធូប នៅតាមវត្តអារាមនិងផ្ទះសំបែង ។

អាស្រ័យដូចបានជំរាបជូនខាងលើ សាលាសង្កាត់គោកចក សូមជូនដំណឹងជាសាធារណៈចាប់ពីពេលនេះតទៅ ។

សូមអរគុណ !

សង្កាត់គោកចក, ធ្វើនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៩